# ផលិតកម្មដំណាំដូងសំរាប់កសិករ



រៀបចំដោយមានការចូលរួមពីអង្គការ សន្តិសេនា សមាគមមនុស្សចាស់ពោធិធំ អង្គការចិត្តធម៌ និង អង្គការ ស៊ី អារ អែស កម្មវិធីកសិកម្ម

ដក់ស្រង់ពីឯកសារឈើហូបផ្លែរបស់អង្គការ ប៉ាដិក ស៊ីដសេ និង សាលាជាតិកសិកម្មព្រែកលៀប

# មាតិការ

ទំព័រ

១- សេចក្តីផ្តើម....................................................................................០១
២- ការជ្រើសរើសពូជ...............................................................................០១
៣- ការបណ្តុះកូន.....................................................................................០២
ក. ជ្រើសរើសទីតាំងថ្នាល.......................................................................០២
ខ. ការបណ្តុះកូនដូង.............................................................................០២
៤- ការដាំដុះ..........................................................................................០៣
ក. ការជ្រើសរើសទីកន្លែងដាំដុះ..................................................................០៣
ខ. របៀបជីករណ្តៅ.................................................................................០៣
គ. ការដាក់ជីក្នុងរណ្តៅ............................................................................០៤
ឃ. ការដាំកូនដូង...................................................................................០៤
៥- ការថែទាំ...........................................................................................០៥
ក. ការដាក់ជីបំប៉ន.................................................................................០៥
ខ. ការស្រោចទឹក...................................................................................០៦
គ. ការការពារជម្ងឺ និង សត្វល្អិតចង្រៃ.......................................................០៦
៦- ការប្រមូលផល.....................................................................................០៦

ម.ព.ឯ.ក AIDOC
Code: ____________
Date: ____________
Donated by: ____________
____________

## ១-សេចក្តីផ្តើម

ដូងជារុក្ខជាតិមួយអាចធ្វើការដាំដុះលើដីច្រើនប្រភេទបាននៅក្នុងប្រទេសកម្ពុជាវាមានអាយុកាលរាប់សិបឆ្នាំ វាផ្តល់ផ្លែក្នុងរយៈពេលប្រហែលបួន ទៅ ប្រាំមួយឆ្នាំក្រោយពេលដាអាស្រយ័លើប្រភេទពូជ ។

ដូងមានប្រយោជន៍ច្រើនយ៉ាងដូចជាៈ- ទឹកសំរាប់ហូបពេលផ្លែនៅខ្ចី ស្លឹកធ្វើសំភារៈប្រើប្រាស់ផ្សេងៗ ដើមធ្វើជាសំនង់ អូសដុត ជាម្លូម់ ប្រេងជាគ្រឿងក្រអូប និង ជាឱសថ និង ជារបាំងខ្យល់ ។

## ២- ការជ្រើសរើសពូជៈ

ដើម្បីអោយទទួលបានផលឆាប់ និង ខ្ពស់យើងត្រូវផ្អែកលើលក្ខណៈសំរាប់ជ្រើសរើសមួយចំនួនដូចជា :- ត្រឡោកធំ មានសាច់ក្រាស រស់ជាតិផ្អែម ក្លិនក្រអូប ធន់ជំម្ងឺ និង សត្វល្អិតចង្រៃ ឆាប់ផ្លែ មានប្រភពច្បាស់លាស់ អាចដាំដុះបាននៅលើដីច្រើនប្រភេទ ក្រឡុកផ្លែមានឮសូរសំលេងទឹកយ៉ាងច្បាស់ និង មានតំលៃខ្ពស់សំរាប់ទីផ្សារ ។



## ៣-<u>ការបណ្ដុះកូនៈ</u>

### ក. <u>ជ្រើសរើសទីតាំងថ្នាលៈ</u>

ដូងងាយស្រួលក្នុងការបណ្ដុះជាងរុក្ខជាតិផ្សេងៗ ដោយគ្រាន់តែរក្សាទុកនៅទីសុវត្ថិភាព ក្បែរប្រភពទឹក ដីទួលមិនលិចទឹក និង កន្លែងមានពន្លឺព្រះអាទិត្យគ្រប់គ្រាន់ជាការស្រេច ។

### ខ.<u>ការបណ្ដុះកូនដូងៈ</u>

ត្រូវកាប់សំបកត្រង់ជ្រុងណាដែលធំជាងផ្នែកខាងក្បាល ដាក់ជ្រុងនោះទៅក្រោម រួចកាប់ចំពីលើសំរាប់អោយមានស្នាមសំរាប់ដូងដុះពន្លក ដាក់ចំបើង ឬ កំទេចកំទីរុក្ខជាតិពង្រាយលើថ្នាលដែលពង្រាបរួច តម្រៀបផ្លែដូងពីលើចំបើង ឬ កំទេចកំទីរុក្ខជាតិពង្រាយរួច គ្របកំណាត់ចំបើងចិញ្ច្រាំខ្លីៗពីលើហើយស្រោចទឹកអោយសើមជាប្រចាំរហូតដល់វាមានអាយុមួយឆ្នាំទើបអាចយកទៅដាំបាន ។



## ៤-ការដាំដុះ

### ក.ការជ្រើសរើសទីកន្លែងដាំដុះ :

ត្រូវដាំដូងនៅកន្លែណាដែលមានសុវត្ថិភាព ដីខ្ពស់មិនលិចទឹកតែមានសំណើម និង មានដីជាតិល្អ ឆ្ងាយពីដើមឈើធំៗដែលមានស្រាប់យ៉ាងហោចណាស់១០ម៉ែត្រមានប្រភពទឹកនៅក្បែរងាយស្រួលក្នុងការស្រោចស្រពនៅពេលជួបប្រទះភាពរាំងស្ងួត ។

### ខ.របៀបជីករណ្តៅ:

រណ្តៅដាំដែលទំហំសមល្មមគឺ ជំរៅមួយម៉ែត្រ បណ្តោយមួយម៉ែត្រ និង ទទឹងមួយម៉ែត្រ គំលាតពីរណ្តៅមួយទៅរណ្តៅមួយយ៉ាងហោចណាស់ ១០ម៉ែត្រហើយ ត្រូវធ្វើយ៉ាងណាកំណត់ជួរអោយប៉ះ និង ពន្លឺព្រះអាទិត្យស្មើគ្នា ។



គ.ការដាក់ជីក្នុងរណ្ដៅ:

ក្រោយពេលជីករណ្ដៅរួច មុនពេលដាំត្រូវប្រមូលសំរាមដែលបានពីរុក្ខជាតិ ផេះ លាមកសត្វ ឬ ជីកំប៉ុសីដាក់ក្នុងរណ្ដៅអោយបានច្រើនជាការប្រសើរព្រោះវាជាជីធម្មជាតិ ដែលផ្ទុកទៅដោយអាហារធាតុចិញ្ចឹមច្រើនយ៉ាង ។

ឃ. ការដាំកូនដូង :

ត្រូវពិនិត្យ និង អនុវត្តិអោយបានហ្មត់ចត់ដូចជាកូនដូងត្រូវមានអាយយ៉ាងតិចមួយឆ្នាំ ដាំនៅពេលល្ងាចដើម្បីអោយវាទទួលសំណើមពេលយប់ និង ស្រោចទឹកដើម្បីអោយឫសឆាប់ចាប់ជាប់និងដីថ្មី ។



# ៥-ការថែទាំ:

## ក.ការដាក់ជីបំប៉ន:

ជីបំប៉ន់ត្រូវដាក់ពីរដងក្នុងមួយឆ្នាំនៅរៀងរាល់ដើម និង ចុងរដូវវស្សា ជីករណ្ដៅរាងមូលដែលមានផ្ចិតប្រវែងប្រាំតឹក និង ជំរៅប្រាំតឹកចំងាយគល់ចំងាយប្រហែលមួយ ទៅ ពីរម៉ែត្រ ដាក់ជីធម្មជាតិ និង ជីគីមីសមាសដែលមានធាតុ អ៊ុន ប៉េ កា ហើយចំពោះការដាក់លើកក្រោយៗទៀតជៀសវាងកុំអោយចំរណ្ដៅដដែល ។

